កិច្ចតែងការ	
មុខវិជ្ជា	សិក្សាសង្គម
ប្រធានបទ	-ស្គាល់ពីអារម្មណ៍មួយចំនួន -សម្តែងអារម្មណ៍ និងចេះសង្កត់ចិត្តរបស់ខ្លួន
ចំណងជើងមេរៀន	ល្បែងក្តារអារម្មណ៍ ដកស្រង់ចេញពីរឿង “យក្សចម្លែក”
កម្រិត	កម្រិតទាប ៣០ នាទី
គោលបំណង	-ប្រាប់បានពីអារម្មណ៍និងមូលហេតុដែលធ្វើអោយខ្លួនសប្បាយត្រេចអ ភ័យ ខ្លាចនៅពេលជួបព្រឹត្តិការណ៍ណាមួយ។ -ប្រាប់ពីអារម្មណ៍ និងគ្រប់គ្រងអារម្មណ៍របស់ខ្លួននៅពេលជួបរឿងមិនសប្បាយចិត្ត និងសប្បាយចិត្តដោយធ្វើកាយវិការ
បំណិនសម្បទា	-បង្ហាញកាយវិការ ឬនិយាយបានអំពីសេចក្តីស្រឡាញ់ និង ទំនាក់ទំនងជាមួយមនុស្សដែលនៅជុំវិញ។ -សម្តែងអារម្មណ៍ផ្ទាល់ខ្លួន និង ស្រឡាញ់ ស្អប់ តាមរយៈកាយវិការ និង ពាក្យសម្តី។ -សម្របខ្លួន និងទប់អារម្មណ៍ មិនអោយឆាប់ខឹងទៅនិងស្ថានភាពមនុស្សជុំវិញ ។
ចរិយាសម្បទា	-ទំនាក់ទំនងល្អទាំងកាយវិការនិង សំដីប្រកបដោយសេចក្តីស្រឡាញ់ជាមួយមនុស្សដែលនៅជុំវិញ ។ -ទទួលស្គាល់បរាជ័យរបស់ខ្លួន និងភាពជោគជ័យរបស់ដៃគូលែងជាមួយមិត្ត។ -កែប្រែទម្លាប់អវិជ្ជមានដើម្បីរស់នៅក្នុងសង្គម។
គ្រូបង្រៀន (ផលិតសម្ភារឧបទេស)	បោះពុម្ពចេញ និងអ៊ុតល្បែងក្តារអារម្មណ៍ ស្វែងរកបរបស់ សម្រាប់រាប់ និងគ្រាប់ឡុកឡាក់ សម្រាប់ល្បែងក្តារនីមួយៗ
កុមារ	អង្គុយជាក្រុមតូចមួយ តាមចំនួនសិស្ស។
រៀបចំ	យកមុខអារម្មណ៍មកបង្ហាញក្មេងៗម្តងមួយៗ គ្រាប់ឡុកឡាក់ និងក្តារអារម្មណ៍។

សកម្មភាពគ្រូបង្រៀន	**មាតិកា**	**សកម្មភាពសិស្ស**
១.សាកសួរក្មេងៗថាពួកគេ មាននៅចាំអារម្មណ៍របស់ រតនា	១. រមៀលគ្រ ប់ឡុកឡាក់ ២. ចាប់ផ្តើមដើរតាមចំនួន លេខរបស់គ្រាប់ឡុកឡាក់	១. ត្រូវស្តាប់គ្រូ និងឆ្លើសំណួររបស់ គ្រូ ។ ២. យកចិត្តទុកដាក់ នៅពេលដែលគ្រូពន្យល់

និងមករានៅក្នុងសៀវភៅរឿង«យក្សចម្លែក» និងពិភាក្សាជាមួយពួកគេ ២. បង្ហាញក្មេងៗពីល្បែងក្តារអារម្មណ៍ និងពន្យល់សេចក្តីណែនាំ។ ៣. ចង្អុលទៅ អារម្មណ៍នីមួយៗនៅលើក្តារអារម្មណ៍ និងឱ្យក្មេងៗប្រសិនបើពួកគេស្គាល់អារម្មណ៍មួយណា នោះ ។ ៤. ប្រាប់ក្មេងៗប្រសិនបើពួកគេមិនស្គាល់ និងឧទាហរណ៍ពីពេលវេលាដែលអ្នកមានអារម្មណ៍បែបនោះ។ ៥.សូមលើកជាឧទាហរណ៍ ២ ឬ៣ ដោយខ្លួនឯងអ្នក ឧទាហរណ៍. ចង្អុលទៅអារម្មណ៍មួយ និងប្រាប់ពួកគេនៅពេលដែលអ្នកមានអារម្មណ៍បែបហ្នឹង។ ៦. ឱ្យក្តារអារម្មណ៍ទៅតាមក្រុមនីមួយៗគ្រាប់ឡកឡាក់ និងរបស់សម្រាប់សម្គាល់កន្លែងរបស់ពួកគេ។ ៧. រំលឹកក្មេងៗថាត្រូវគោរពចម្លើយរបស់អ្នកផ្សេងៗ។ អ្នកទាំងអស់ គ្នាគឺខុសប្លែកពីគ្នាបទពិសោធន៍ផ្សេ ង ៗ ពី គ្នា។ អ្វីដែលអ្នកខ្លាចមិនប្រាកដ ថាគេខ្លាចដែរនោះទេ ។ ពួកយើងទាំងអស់គ្នាមិនមែនចូលចិត្តអារហារដែលដូចគ្នានោះទេ ។ -ល-។ 8. ឱ្យក្មេងៗលេ ងបៃ បនេះច្រើនដងជាការស្រេច។	៣. ប្រាប់ទៅក្មេងៗនៅក្នុងក្រុមពីឱកាសមួយនៅពេលដែលក្មេងៗមានអារម្មណ៍ដូចនឹងប្រអប់ដែលក្មេងៗបានដើរដល់។	និងបង្ហាញពីល្បែងក្តារអារម្មណ៍។ ៣.ជ្រើសរើសនរណាម្នាក់ដើម្បីចាប់ផ្តើមលេងល្បែងនោះ។ ៤. ផ្លាស់ប្តូរវេន។ ៥.ឱ្យគ្រាប់ឡកឡាក់ទៅក្មេងបន្ទាប់នៅពេលដែលបានរមៀលវាហើ យ ៦. លើកជាឧទាហរណ៍ពីអារម្មណ៍។ ប្រសិនបើអ្នកគ្មានអារម្មណ៍ទេសូមព្យាយាម និងលើកឧទាហរណ៍នៅពេលអ្នកគិតថានរណាម្នាក់នឹងមានអារម្មណ៍ បែបហ្នឹង។ ៧.ស្តាប់ដោយយកចិត្តទុកដាក់ ចំពោះឧទាហរណ៍ពួកយើងទាំងអស់គ្នាគឺខុសគ្នា និង មានបទពិសោធន៍ផ្សេងៗគ្នា។